**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ: [illegible] សហវ.[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដោយទីចាត់ការគយ និងរដ្ឋាករ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ១១៣ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការគ្រប់គ្រងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀតស្តីពីការនាំចេញ និងនាំចូល
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដោយទីចាត់ការគយ និងរដ្ឋាករត្រូវអនុវត្តដោយអនុលោមតាមបញ្ញត្តិមាត្រា ១៨ មាត្រា ៥២ និងមាត្រា ៥៧ នៃច្បាប់ស្តីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដោយទីចាត់ការគយ និងរដ្ឋាករគឺជាការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬការត្រួតពិនិត្យឡើងវិញដែលមានលក្ខណៈជាប្រព័ន្ធដោយមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចដើម្បីធ្វើការផ្ទៀងផ្ទាត់នូវភាពត្រឹមត្រូវ និងស្របច្បាប់នៃប្រតិវេទន៍គយ តាមរយៈការត្រួតពិនិត្យនូវឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងៗទៀតដែលបុគ្គលដូចមានចែងក្នុងបញ្ញត្តិប្រការ ៦ នៃប្រកាសនេះត្រូវរក្សាទុក ស្របតាមបញ្ញត្តិប្រការ ១ នៃប្រកាសស្តីពី ការគ្រប់គ្រងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងៗទៀតស្តីពីការនាំចេញ និងនាំចូលដូចយោងខាងលើ ។

**ប្រការ ៣.-**

សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដោយទីចាត់ការគយ និងរដ្ឋាករមានគោលបំណងដើម្បីធានាថា បុគ្គលដូចមានចែងក្នុងបញ្ញត្តិប្រការ ៦ នៃប្រកាសនេះ អនុលោមបានពេញលេញទៅតាមច្បាប់ស្តីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។ គោលបំណងនេះក៏ដើម្បីធានាផងដែរថា :

- រាល់ការនាំចេញ និងការនាំចូលទាំងអស់ត្រូវបានប្រកាសយ៉ាងត្រឹមត្រូវដល់រដ្ឋបាលគយ

- ទំនិញដែលស្ថិតនៅក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ត្រូវបានគ្រប់គ្រងឱ្យនាំចេញ និងនាំចូល និងត្រួតពិនិត្យតាមបទប្បញ្ញត្តិច្បាប់ជាធរមាន

- ពន្ធ និងអាករពាក់ព័ន្ធនឹងការបង្វែរគម្រោងបង្ហាប់អនុគ្រោះរបស់ទំនិញ ឬការដាក់ឱ្យប្រើប្រាស់ក្នុងប្រទេសនូវទំនិញដូចនេះ ត្រូវបានបង់ដោយត្រឹមត្រូវ ហើយលក្ខខណ្ឌនៃការសម្រេចចិត្តដូចនេះ ត្រូវបានធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន

- ប្រតិវេទន៍ករបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាទុកឯកសារទាំងអស់សម្រាប់រយៈពេលដូចដែលមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់ជាធរមាន

-ទំនិញទាំងអស់ដែលស្ថិតក្រោមរបបកណ្តាគារគយមានដែនកំណត់និងក្រោមរបបព្យួរពន្ធផ្សេងទៀតត្រូវបានបំពេញទម្រង់ការគយបានត្រឹមត្រូវ ហើយលក្ខខណ្ឌ និងការតម្រូវផ្សេងទៀតនៃរបបទាំងនេះត្រូវបានអនុលោមតាម

- ផ្ទៀងផ្ទាត់នូវភាពត្រឹមត្រូវ និងភាពស្របច្បាប់នៃប្រតិវេទន៍គយ ។

**ប្រការ ៤.-**

បុគ្គលដូចមានចែងក្នុងបញ្ញត្តិប្រការ ៦ នៃប្រកាសនេះត្រូវទទួលខុសត្រូវក្នុងការប្រកាសឲ្យបានត្រឹមត្រូវនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត និងតម្លៃគិតពន្ធគយនៃទំនិញដើម្បីជាមូលដ្ឋានក្នុងការបង់ប្រាក់ពន្ធ និង/ឬអាករ ។ បុគ្គលទាំងនេះត្រូវបញ្ចេញរាល់ព័ត៌មាន វិក្កយបត្រ និងឯកសារផ្សេងទៀត ដើម្បីឲ្យរដ្ឋបាលគយអាចផ្ទៀងផ្ទាត់ និងធ្វើការកំណត់ឱ្យបានត្រឹមត្រូវនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត និងតម្លៃគិតពន្ធគយនៃទំនិញ ។

ក្នុងរយៈពេលបី (៣) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ តាមរយៈការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬការត្រួតពិនិត្យឡើងវិញនូវទំនិញ មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចអាចកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬតម្លៃគិតពន្ធគយនៃទំនិញដែលបានប្រកាសដោយចេញនូវប្រវេសន៍ ។ ប្រវេសន៍ត្រូវមានចែងអំពីហេតុផលនៃការកំណត់ឡើងវិញនេះ ។

នៅពេលដែលការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬការត្រួតពិនិត្យឡើងវិញ ត្រូវបានធ្វើឡើងនៅក្រោមប្រការនេះ បានរកឃើញនូវសកម្មភាពខុសឆ្គងណាមួយនោះ ប្រវេសន៍អាចត្រូវបានចេញដោយមន្ត្រីគយ និងរដ្ឋាករមាន

សមត្ថកិច្ច ចំពោះតែទំនិញដែលស្ថិតនៅក្រោមការស៊ើបអង្កេតក្នុងរយៈពេលមិនលើសពីដប់ ( ១០ ) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

**ប្រការ ៥ .-**

តាមសំណើរបស់រដ្ឋបាលគយ បុគ្គលដូចមានចែងក្នុងបញ្ញត្តិប្រការ ៦ នៃប្រកាសនេះមានកាតព្វកិច្ចត្រូវផ្តល់បង្ហាញនូវឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់របស់គយ ។

ប្រសិនបើបុគ្គលដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌទី ១ នៃប្រការនេះ អវត្តមាន អ្នកតំណាងរបស់បុគ្គលនោះមានកាតព្វកិច្ចក្នុងការផ្តល់នូវឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀត ។

ក្នុងករណីដែលមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចតម្រូវ បុគ្គលដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌខាងលើនៃប្រការនេះត្រូវ ៖

ក- ផ្តល់នូវឯកសារ ដូចមានចែងក្នុងបញ្ញត្តិប្រការ ៤ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀតស្តីពីការនាំចេញ និងនាំចូលដូចយោងខាងលើ ។

ខ- ឆ្លើយរាល់សំណួរដែលត្រូវបានសួរដោយមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការទាំងឡាយដែលកើតឡើងក្រោមបញ្ញត្តិនៃប្រកាសនេះ។

គ- បើកឱ្យដំណើរការនូវរាល់ឧបករណ៍ ដើម្បីផ្តល់ បង្ហាញ នូវព័ត៌មានចាំបាច់នានាដល់មន្ត្រីគយមានសមត្ថកិច្ចតាមសំណើ ប្រសិនបើព័ត៌មានដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌខាងលើនៃប្រការនេះ ត្រូវបានរក្សាទុកដោយមធ្យោបាយអេឡិចត្រូនិក ឬឧបករណ៍ផ្សេងទៀត ។

**ប្រការ ៦.-**

សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដោយទីចាត់ការគយ និងរដ្ឋាករ ត្រូវអនុវត្តចំពោះបុគ្គលដែលចូលរួម ឬពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ

ដែលរាប់បញ្ចូលទាំងអ្នកនាំចូល អ្នកនាំចេញ ដេីងសារគយ ប្រតិបត្តិករសន្និធិគយបណ្តោះអាសន្ន ប្រតិបត្តិករឃ្លាំងគយមានដែនកំណត់ ក្រុមហ៊ុនដឹកជញ្ជូនទំនិញ ឬ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការនាំចូល ឬការនាំចេញ ។

**ប្រការ ៧.-**

បុគ្គលដូចមានចែងក្នុងបញ្ញត្តិប្រការ ៦ នៃប្រកាសនេះ ត្រូវសហការជាមួយមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ក្នុងការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ។

តាមពេលវេលាដែលច្បាប់អនុញ្ញាត មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចមានសិទ្ធិចូលក្នុងទីតាំង ឬទីកន្លែងដែលរក្សាទុកឯកសារ ដូចមានចែងក្នុងបញ្ញត្តិមាត្រា ៥១ នៃច្បាប់ស្តីពីគយ ហើយមានសិទ្ធិធ្វើសវនកម្ម ឬពិនិត្យផ្ទៀងផ្ទាត់ឯកសារទាំងនោះដែលពាក់ព័ន្ធនឹងកិច្ចចម្លងការដោយឡែក ឬភាពត្រឹមត្រូវ និងអាចទទួលយកបាននៃប្រព័ន្ធកត់ត្រាដោយដៃ ឬប្រព័ន្ធអេឡិចត្រូនិកដែលនៅក្នុងប្រព័ន្ធនោះឯកសារទាំងនេះត្រូវបានបង្កើត និងរក្សាទុក ។

មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច អាចធ្វើអធិការកិច្ចបានលើឯកសារកំណត់ត្រា និងព័ត៌មានផ្សេងទៀត ឬទ្រព្យសម្បត្តិ កិច្ចដំណើរការ ឬកិច្ចការផ្សេងទៀតដែលមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចយល់ថាចាំបាច់ និងពាក់ព័ន្ធនឹងគោលដៅនៃការប្រមូលពន្ធ និងអាករ ក្រោមបញ្ញត្តិនៃច្បាប់ស្តីពីគយ សម្រាប់អនុវត្តតាមគោលបំណងបំពេញនូវភារកិច្ចរបស់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ឬក្នុងគោលបំណងនៃការប្រមូលព័ត៌មានដែលតម្រូវដោយច្បាប់ស្តីពីគយ ។

មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច មានសិទ្ធិចេញ និងចូលទៅគ្រប់ទីតាំង កន្លែង អគារ និងទីកន្លែងនានា ព្រមទាំងមានសិទ្ធិផ្ទៀងផ្ទាត់ ឯកសារ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ទោះបីជាស្ថិតក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់អ្នកទទួលបានអាជ្ញាប័ណ្ណ អ្នកនាំចេញ ឬអ្នកនាំចូល ឬបុគ្គលណាផ្សេងទៀតក៏ដោយ ។

មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច អាចដកស្រង់ព័ត៌មាន ឬថតចម្លងនូវកំណត់ត្រា ឬឯកសារនានា ដកហូតយកដោយមានកំណត់ហេតុ និងរក្សាទុកឯកសារដែលបានបង្ហាញពាក់ព័ន្ធនឹងការប្រកាសណាមួយ ឬតាមតម្រូវការនៃច្បាប់ស្តីពីគយដោយគ្មានជាប់បន្ទុកចំណាយអ្វីឡើយ ។

តាមសំណើរបស់ជនដែលកាន់កាប់ឯកសារ មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចត្រូវផ្តល់ដល់ជននោះនូវឯកសារថតចម្លងត្រឹមត្រូវ ដោយមានការបញ្ជាក់ពីមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ។

**ប្រការ ៨.-**

នៅពេលបញ្ចប់ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយប្រសិនបើមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចពុំបានរកឃើញនូវតម្រុយណាមួយនៃការរំលោភលើច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន មន្ត្រីគយ និងរដ្ឋាករពាក់ព័ន្ធត្រូវបំពេញក្នុងរបាយការណ៍សវនកម្មជាបន្ទាន់ និងបញ្ឈប់ការធ្វើសវនកម្មនេះ ។

នៅពេលបញ្ចប់ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយប្រសិនបើមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចបានរកឃើញនូវបទល្មើសណាមួយលើច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន មន្ត្រីគយ និងរដ្ឋាករពាក់ព័ន្ធត្រូវធ្វើកំណត់ហេតុជាលាយល័ក្ខអក្សរស្តីពីបទល្មើសនេះ និងត្រូវដកស្រង់ព័ត៌មាន ឬថតចម្លងនូវកំណត់ត្រា ឬឯកសារនានា ដកហូតយកដោយមានកំណត់ហេតុ និងរក្សាទុកឯកសារដែលបានបង្ហាញតាមតម្រូវការស្របតាមបញ្ញត្តិនានានៃប្រកាសនេះ ដោយគ្មានជាប់បន្ទុកចំណាយអ្វីឡើយ ។ កំណត់ហេតុ និងឯកសារដែលដកហូតទាំងនេះត្រូវបញ្ជូនទៅថ្នាក់ដឹកនាំ ការិយាល័យ សាខា និងទីស្នាក់ការគយ និងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីចាត់វិធានការតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**ប្រការ ៩.-**

បុគ្គលដូចមានចែងក្នុងបញ្ញត្តិប្រការ ៦ នៃប្រកាសនេះដែលមិនពេញចិត្តចំពោះការសម្រេចរបស់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ឬមិនពេញចិត្តលើការកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬតម្លៃគិតពន្ធគយ

ដែលបានផ្តល់ជូនក្នុងប្រវេសន៍ ដូចមានចែងក្នុងបញ្ញត្តិនៃប្រកាសនេះ អាចជំទាស់ទៅនឹងការសម្រេចនេះជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយ និងរដ្ឋាករ ដោយអនុលោមតាមបញ្ញត្តិមាត្រា ២៤ ឬមាត្រា ៧១ នៃច្បាប់ស្តីពីគយ ។

**ប្រការ ១០.-**

នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវចេញសេចក្តីណែនាំចាំបាច់នានាស្តីពីនីតិវិធីនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ សំដៅធានាឲ្យមានតម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ ។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១២
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ